**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia

តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# បេសកកម្មរបស់លោកតំណាងពិសេស នៃលោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ថ្ងៃទី២៨ ខែវិច្ឆិកា ដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៥

*ភ្នំពេញថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៥* -- លោក **យ៉ាសហ៊ា ហ្គាយ** តំណាងពិសេស នៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ចប់បេសកកម្មលើកទីមួយរបស់លោកនៅកម្ពុជានាថ្ងៃនេះ ។ នៅក្នុងអំឡុងពេលទស្សនៈកិច្ចរបស់លោក លោកតំណាងពិសេសបានចូលគាល់ព្រះមហាក្សត្រ និងបានជួបជាមួយតំណាងជាន់ខ្ពស់របស់រាជរដ្ឋាភិបាល រួមទាំងប្រធានព្រឹទ្ធសភា និង រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ លោកបានជួបផងដែរ ជាមួយអាជ្ញាធរតុលាការ តំណាងគណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និង អង្គការសហគមន៍ សហជីពកម្មករ អ្នកសំរបសំរួលអ.ស.ប និង ក្រុមមន្ត្រីអង្គការសហប្រជាជាតិនៅកម្ពុជា ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេភាគី និង ពហុភាគី និងសហគមន៍អ្នកការទូតនានា ។ លោកបានចូលជួបលោក **ជាម ច័ន្ទនី** សមាជិករដ្ឋសភា នៅក្នុងពន្ធនាគារយោធា និងលោក **ម៉ម សូ ណាង់ដូ** អ្នកផ្សាយព័ត៌មានវិទ្យុ និងលោក **រ៉ុង ឈុន** ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជានៅក្នុងពន្ធនាគារព្រៃស ។ លោកតំណាងពិសេសបានបង្រៀនអំពី "រដ្ឋធម្មនុញ្ញ និង លិទ្ធិប្រជាធិបតេយ្យភាវូបនីយកម្ម " នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ លោកបានពិភាក្សាអំពីបញ្ហាមួយចំនួនពាក់ព័ន្ធនឹងដីធ្លី និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ជាមួយអង្គការក្រៅរដ្ឋាភិបាលថ្នាក់ខេត្ត និងក្រុមសហគមន៍នានានៅក្នុងខេត្តកំពង់ស្ពឺ ។ លោកតំណាង ពិសេសក៏បានចូលរួមផងដែរ នៅក្នុងកម្មវិធីតាមវិទ្យុស្តីពីទិវាសិទ្ធិមនុស្ស ។

នៅក្នុងអំឡុងពេលបេសកកម្មរបស់លោក លោក**ហ្គាយ**បានធ្វើការស្វែងយល់អំពីសភាពការណ៍ទូទៅខាងសិទ្ធិមនុស្សនៅកម្ពុជា ។ លោកបានយកចិត្តទុកដាក់ជាពិសេសចំពោះរដ្ឋធម្មនុញ្ញកម្ពុជា វិស័យយុត្តិធម៌ និងសេរីភាពនៃការបង្កើតសមាគម សេរីភាពនៃការប្រជុំ និង សេរីភាពក្នុងការសំដែងមតិ ។ នៅក្នុងបញ្ហានេះដែរ មានមនុស្សជាច្រើន បានសំដែងនូវការព្រួយបារម្ភអំពីការប្រើបញ្ញត្តិស្តីពីការបរិហាកេរ្តិ៍ ការញ៉ុះញ៉ង់ និងការផ្សាយព័ត៌មានមិនពិត នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល "ច្បាប់អ៊ុនតាក់" ។ លោកបានឮពាក្យរអ៊ូរទាំជាច្រើនអំពីកិច្ចដំណើរការនៃប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការចាប់ខ្លួននិងការឃុំខ្លួនឥស្សរជននយោបាយ អ្នកកាសែត និងប្រធានសហជីពកម្មករ ហើយនិងការដកអភ័យឯកសិទ្ធិសមាជិកសភានៃគណបក្សប្រឆាំងមួយចំនួន ។ មានការសំដែងការព្រួយបារម្ភពីការលំបាកជាច្រើនទៀត ដែលសហគមន៍ជនបទនានាកំពុងជួបប្រទះក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន ដោយសារការបាត់បង់ដីធ្លី និងសិទ្ធិប្រើប្រាស់ធនធានធម្មជាតិ ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានប្រាប់លោកតំណាងពិសេសពីការលំបាកដែលពួកគេជួបប្រទះក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងការកើនឡើងនៃការិតត្បិតទៅលើការអនុវត្តន៍សេរីភាពក្នុងការបង្កើតសមាគម សេរីភាពក្នុងការប្រជុំ និងសេរីភាពក្នុងការសំដែងមតិ ។ លោកតំណាងពិសេសនឹងលើកយកបញ្ហាទាំងនេះទៅពិភាក្សាជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

បន្ទាប់ពីការបំពេញបេសកកម្មរបស់លោក លោកតំណាងពិសេសនឹងរៀបចំរបាយការណ៍មួយ ភ្ជាប់ជាមួយនូវអនុសាសន៍មួយចំនួនរបស់លោក ដើម្បីដាក់ជូនគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ។

ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៥

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧